# រឿង
# ក្តីស្រមៃរបស់ខាន់វ៉ា
# CANVA'S DREAM

យ៉ាន ស្រីលីន
ម៉ាន់ ម៉ាឡៀន



# ក្តីស្រមៃរបស់ខាន់វ៉ា (CanVa's Dream)

**Written by** Yan Sreylin
**Artwork by** Mann Malen

**Co-Editors** Sai Yee Tip,
Prak Monirath,
Uoeung Bonsovathary

**Art Editor** San Somanear

**Reviewed by** Khmer Youth Association (KYA),
Love is Diversity

Publisher Khmer Youth Association (KYA)
No. 32D, St. 562, Phnom Penh12151, Cambodia

Copyright © 2024 by Khmer Youth Association (KYA)

All rights reserved.
Without limiting the rights under the copyright reserved above, no part of this publication may be reproduced, stored in or introduced into a retrieval system, or transmitted, in any form, or by any means (electronic, mechanical, photocopying, recording, or otherwise), without the prior written permission of the copyright owner.
Published in Phnom Penh, Cambodia.

A catalog record for this book is available from
the National Library of Cambodia
ISBN: 978-9924-9966-0-6

Disclaimer: This storybook is made possible by the generous support of the American people through the United States Agency for International Development (USAID)-funded Civil Society Support (CSS) Activity implemented by Family Health International (FHI360). The contents are the responsibility of Khmer Youth Association and do not necessarily reflect the views of USAID or the United States Government.

# រឿង
# ក្តីស្រមៃរបស់ខាន់វ៉ា
## CANVA'S DREAM



ខាន់វ៉ា គឺជាក្មេងប្រុសជនជាតិចារាយម្នាក់ដែលមានចរិតស្លូតបូត
សុភាពរាបសា ហើយចូលចិត្តជួយយកអាសាអ្នកដទៃ។



សព្វថ្ងៃ ខាន់វ៉ាកំពុងរៀនថ្នាក់ទី៩ នៅអនុវិទ្យាល័យ នៅក្នុងសហគមន៍
ដាច់ស្រយាលមួយស្ថិតនៅភូមិប៉ក់ធំ ឃុំប៉ក់ញ៉ៃ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។





ជារឿយៗ ខាន់រ៉ាចូលចិត្តលេងជាមួយក្មេងស្រីៗ និងចូលចិត្ត
តុបតែងខ្លួនជាស្រីក្នុងឈុតប្រពៃណីរបស់គេ



ដើម្បីសម្ដែងជូនភ្ញៀវទេសចរណ៍ ដែលមកទស្សនារៀងរាល់ចុងសប្ដាហ៍
នៅរមណីយដ្ឋានជនជាតិដើមភាគតិច។





ការងារជាអ្នកសម្តែងនេះ ខាន់វ៉ាអាចរកកម្រៃបានខ្លះសម្រាប់ផ្គត់ផ្គង់ការសិក្សា និងជីវភាពគ្រួសារមួយកម្រិតផងដែរ។





នៅក្នុងសហគមន៍ បែរជាមិនពេញចិត្ត
នឹងទង្វើរបស់ខាន់រ៉ាទៅវិញ។



ចំណែកឪពុកម្តាយរបស់ខាន់រ៉ាវិញ ត្រូវបានគេមាក់ងាយនៅពេល
ដែលគាត់ទៅចេញទៅក្រៅ ឬទៅផ្សារម្តងៗ



ពួកគាត់ត្រូវបានគេមាក់ងាយ ព្រមទាំងស្តីបន្ទោសដោយថាពួកគេ មិនចេះប្រដៅកូន។



ប៉ុន្តែឪពុកម្តាយរបស់ខាន់វ៉ាតែងតែគាំទ្រ និងរីករាយជាមួយនឹងភាពប៉ិនប្រសប់របស់កូនជានិច្ច ប៉ុន្តែពួកគាត់ក៏មានក្តីព្រួយបារម្ភអំពីអនាគតខាន់វ៉ាផងដែរ ដែលគេតែងតែតុបតែងខ្លួនជាស្រី និងមានលក្ខណៈជាស្រីខុសពីក្មេងប្រុសដទៃ។



អស់រយៈពេលច្រើនឆ្នាំមកហើយ ឪពុកម្ដាយរបស់ខាន់រ៉ាតែងតែព្យាយាម ឱ្យខាន់រ៉ាកែប្រែចរិតនេះចេញ ព្រោះវាបានប៉ះពាល់ដល់កិត្តិយសគ្រួសារទាំងមូល។



ពិបាកចិត្ត ខាន់រ៉ាអង្គុយនៅក្រោមដើមប័រ ហើយគិតតែម្នាក់ឯង។ គេអង្គុយត្រមង់ត្រមោចតែម្នាក់ឯង អមដោយទឹកមុខស្រពោន និងគិតពីអនាគតរបស់គេ។




ខ្ញុំជឿជាក់ថា មានតែការសិក្សាប៉ុណ្ណោះ ដែលអាចធ្វើឱ្យខ្ញុំសម្រេចបំណងរបស់ខ្ញុំបាន។
ខ្ញុំត្រូវរៀនឱ្យចប់ ខ្ញុំត្រូវមានការងារល្អ ខ្ញុំត្រូវមានប្រាក់ខែសមរម្យ។
ពេលនោះ ខ្ញុំនឹងអាចកសាងវិទ្យាល័យជូនសហគមន៍ខ្ញុំបានជាក់ជាមិនខានឡើយ។

ព្រលឹមស្រាងៗ ខាន់វ៉ាដើរទៅរៀនតែម្នាក់ឯង។ ភ្លាមនោះ គេ
បានប្រទះឃើញមិត្តរួមថ្នាក់គេម្នាក់កំពុងតែជិះកង់ទៅរៀន។



ខាន់វ៉ាងក់ក្បាលយល់ព្រមជាសញ្ញា ហើយក៏បន្តដើរទៅរៀន
ទាំងក្ដីមន្ទិលនៅក្នុងចិត្ត។



នៅសាលារៀន ពេលដែលខាន់រ៉ាដើរទៅណាមកណា គ្រប់គ្នាតែងតែនាំគ្នាលួចដៀងភ្នែកមើល ហើយសើចចម្អកគ្រប់សកម្មភាពទាំងអស់។



នៅក្នុងថ្នាក់ អ្នកគ្រូបានប្រកាសជ្រើសរើសប្រធានថ្នាក់ថ្មី ដោយឱ្យ
គ្រប់គ្នាលើកដៃស្ម័គ្រចិត្ត។



ខាន់រ៉ាសប្បាយចិត្តណាស់ គេក៏លើកដៃភ្លាមដោយឥតស្ទាក់ស្ទើរអ្វីឡើយ។



រំពេចនោះគ្រប់គ្នាក៏សើចគិល លាន់ឮពេញបន្ទប់។







ខាន់រ៉ាទម្លាក់ទឹកមុខចុះ ព្រោះគ្មាននរណាម្នាក់បោះឆ្នោតឱ្យខ្លួន
សូម្បីតែម្នាក់។


ខាន់រ៉ាឱ្យអ្នកគ្រូសុំទោសផងអ្នកគ្រូចង់ឱ្យកូន
ធ្វើជាប្រធានថ្នាក់ដែរ តែមិនមាននរណាម្នាក់
បោះឆ្នោតគាំទ្រប្អូនសោះ។ អ្នកគ្រូសង្ឃឹមថា
ប្អូននឹងមានឱកាសក្រោយៗទៀត។

ពេលនោះខាន់រ៉ាក៏ដឹងក្នុងចិត្តស្រាប់ហើយថាមកពីគេដូចជា ក្មេងស្រីទើបគ្រប់គ្នាមិនគាំទ្រ។ គេក៏មានគំនិតល្អមួយ ក្នុងការ ប្រាប់ពីរឿងរ៉ាវទាំងអស់ដែលបានកើតឡើងមកលើគេឱ្យទៅជា សាច់រឿងក្នុងរបាំ។





ថ្ងៃអាទិត្យនេះ ខាន់វ៉ាបានតែងខ្លួនសម្តែងជូនភ្ញៀវទេសចរណ៍ដូចសព្វមួយដង។ ប៉ុន្តែថ្ងៃនេះ ខាន់វ៉ាបានបន្ថែមសាច់រឿងថ្មី ដោយយកសាច់រឿងពិតរបស់ខ្លួនដែលត្រូវបានគេផាត់ចេញ ហើយប្រឹងក្រោកតស៊ូដោយស្នាមញញឹម យកមកសម្តែងជូនភ្ញៀវទស្សនា។





ពេលនោះគ្រប់គ្នាទះដៃហ៊ោកញ្ជៀវ ហើយស្រែកថា
**«ខាន់វ៉ា ខាន់វ៉ា ខាន់វ៉ា! ពួកយើងគាំទ្រខាន់វ៉ាជានិច្ច!»**





ភ្ញៀវទាំងអស់ទះដៃអបអរខាន់វ៉ា







ពួកគេបានថតរូបភាពនៃការសម្តែងរបស់ខាន់រ៉ា ហើយបានយក ទៅបង្ហោះនៅក្នុងបណ្តាញសង្គម ធ្វើឱ្យផ្ទុះការចាប់អារម្មណ៍យ៉ាង ខ្លាំងពីសំណាក់មហាជន។





អ្នកសារព័ត៌មានជាច្រើនបានចុះមកជួបខាន់រ៉ាផ្ទាល់។
តើក្តីស្រមៃធំរបស់ប្អូនជាអ្វីទៅ?
ទោះបីលំបាកប៉ុណ្ណា ហើយទោះបីអ្នកផ្សេងគិតថាមិនអាចទៅរួចក៏ដោយ ក៏ខ្ញុំនៅតែបន្តក្តីស្រមៃខ្ញុំជានិច្ច។ ហើយវាមិនមែនតែក្តីស្រមៃរបស់ខ្ញុំតែម្នាក់ឯងទេ វាជាក្តីស្រមៃរបស់ក្មេងៗនៅក្នុងសហគមន៍នេះ។ គ្មានវិទ្យាល័យទេ ដែលជាហេតុធ្វើឱ្យក្មេងៗជាច្រើនរស់នៅក្នុងសហគមន៍នេះ សំរេចចិត្តបោះបង់ការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់ទី៩ ព្រោះវិទ្យាល័យនៅឆ្ងាយពិបាកធ្វើដំណើរ មិនមានសុវត្ថិភាព ហើយគ្រួសារក៏មានជីវភាពខ្វះខាតច្រើនផងដែរ។

ក្រោយមក អ្នកសារព័ត៌មានបានផ្តិតយកទិដ្ឋភាពនៅក្នុង
សហគមន៍ទាំងមូល និងកិច្ចសម្ភាសន៍របស់ខាន់រ៉ាទៅផ្សព្វផ្សាយ



ក្រោយពីឃើញបទសម្ភាសន៍នេះ គ្រប់គ្នារំជួលចិត្តជាខ្លាំងចំពោះក្តី
ស្រមៃរបស់ខាន់រ៉ាដែលតាំងចិត្តមិនបោះបង់ដើម្បីសហគមន៍របស់គេ





ក្រោយមកក៏មានសប្បុរសជន រួមទាំងអង្គការមនុស្សធម៌
មួយចំនួនធំបានចុះមកចូលរួមជាមួយមូលនិធិរបស់ខាន់វ៉ា ហើយ
ថែមទាំងជួយកសាងវិទ្យាល័យថែមទៀតផង។



ខាន់រ៉ាបានរៀបកន្លែងមូលនិធិមួយនៅកន្លែងសម្តែង ហើយមាន
អ្នកភូមិ និងអ្នកមកទស្សនាកំពុងបរិច្ចាគលុយទៅក្នុង
ហិបមូលនិធិ។



អង្គការមួយចំនួនក៏មានការសហការ ដោយសកម្មភាពចុះជួយក្នុង
សហគមន៍មានចែកជាកង់ សៀវភៅ និងកាតាប។ល។



ចំណែកខាន់រ៉ាកាន់តែសប្បាយចិត្ត ព្រោះទាំងខាន់រ៉ា និងក្មេងៗ
នៅក្នុងភូមិនឹងមិនមានអ្នកបោះបង់ការសិក្សាទៀតឡើយ។



ចាប់តាំងពីពេលនោះមក អ្នកទេសចរណ៍កាន់តែច្រើនឡើងៗ ដែលធ្វើឱ្យបងប្អូនក្នុងសហគមន៍មានការងារធ្វើគ្រប់ៗគ្នា។



ចុងក្រោយ អ្នកនៅក្នុងភូមិមានការកោតសរសើរចំពោះខាន់រ៉ា
យ៉ាងខ្លាំង ហើយអ្នកដែលធ្លាប់តែមិនពេញចិត្តនឹងខាន់រ៉ាកន្លងមក
ក៏ប្រែមកជាចូលចិត្តខាន់រ៉ា ហើយថែមទាំងអនុញ្ញាតឱ្យកូនៗរបស់
ពួកគេមករាប់អាន និងយកគំរូល្អៗពីខាន់រ៉ាថែមទៀតផង។





ពួកគេជិះកង់ថ្មីដែលទទួលបានពីសប្បុរជនទៅរៀន
ជាមួយគ្នាយ៉ាងរីករាយ។



ខាន់រ៉ា និងក្មេងៗឯទៀតដែលបានបញ្ចប់ថ្នាក់អនុវិទ្យាល័យ ហើយក៏បានចូលរៀនថ្នាក់វិទ្យាល័យគ្រប់ៗគ្នា។



ខាន់រ៉ាសប្បាយចិត្តដែលគេ និងក្មេងៗឯទៀតទីបំផុតមានសាលាវិទ្យាល័យរៀនបន្តទៀត ។

"គេបានសំរេចក្តីស្រមៃរបស់គេហើយ"





ISBN: 978-9924-9966-0-6